**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិ

## នៃក្រសួងផែនការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា នាយកដ្ឋានគណនេយ្យជាតិ និងនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ ចំណុះវិទ្យាស្ថានជាតិស្ថិតិ បំពេញបន្ថែមលើអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ ។

## ជំពូកទី២

## រចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា ២.-**

នាយកដ្ឋាននីមួយៗ ដែលមានចែងក្នុងមាត្រា ១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

## ជំពូកទី៣

## ភារកិច្ច

**មាត្រា ៣.-**

នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំ និងចងក្រងចំណាត់ថ្នាក់ស្តង់ដារស្ថិតិជាតិ ដើម្បីបម្រើឱ្យការផលិតទិន្នន័យជំរឿន អង្កេត និងការវិភាគ

- រៀបចំ និងចងក្រងទស្សនាទាន និយមន័យស្ថិតិជាតិ

- រៀបចំ និងចងក្រងវិធីសាស្ត្រស្ថិតិរបស់ស្ថិតិផ្លូវការតាមវិស័យ ដើម្បីធានាដំណើរការផលិតទិន្នន័យស្ថិតិផ្លូវការឱ្យបានត្រឹមត្រូវ មានគុណភាព និងគួរទុកចិត្តបាន

- សម្របសម្រួលក្នុងការអនុវត្តចំណាត់ថ្នាក់ស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ដើម្បីឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងអនុវត្តឱ្យបានឯកភាពគ្នា

- វិភាគស្ថិតិស៊ីជម្រៅ តាមប្រធានបទដែលបានពីការអង្កេត និងជំរឿន ដូចជា ភាពក្រីក្រ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការប្រើប្រាស់ពេលវេលា អាហារូបត្ថម្ភ ពលកម្មកុមារ និងប្រធានបទចាំបាច់ផ្សេងទៀត

- ស្រាវជ្រាវ និងចងក្រងព័ត៌មានស្ថិតិសំខាន់ៗតាមសំណូមពរ និងតាមតម្រូវការរបស់អ្នកប្រើប្រាស់ អ្នកធ្វើគោលនយោបាយ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ

- ផ្សព្វផ្សាយវិធីសាស្ត្រនៃការវិភាគស៊ីជម្រៅ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល

- ទទួលបន្ទុកធ្វើបញ្ជីឈ្មោះទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល

- ផ្តល់សេវាកម្មស្រាវជ្រាវ និងវិភាគស្ថិតិតាមសំណូមពរ និងសេចក្តីត្រូវការរបស់ស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ។

**មាត្រា ៤.-**

នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ដំឡើង កែលម្អ ថែទាំ ជួសជុលប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង និងទំនាក់ទំនងបញ្ជូន ព្រមទាំងទទួលព័ត៌មាន និងទិន្នន័យពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដោយធានាផ្តល់នូវសុវត្ថិភាពទិន្នន័យក្នុងប្រព័ន្ធស្ថិតិ និងសេវាផ្សេងទៀត ដូចជាអ៊ិនធឺណេត អ៊ីម៉ែល ការរក្សា ការបែងចែកឯកសារ និងការបោះពុម្ពឯកសារ

- វិភាគតម្រូវការការងារគ្រោង អភិវឌ្ឍប្រព័ន្ធ និងដំឡើងកម្មវិធី ដោយរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ កែតម្រូវបញ្ហា សម្អាតទិន្នន័យ បំប្លែងជាទិន្នន័យមូលដ្ឋាន ព្រមទាំងត្រួតពិនិត្យផ្នែកទន់ សម្រាប់ការងារអង្កេត និងជំរឿន

- បង្កើត រៀបចំ ថែរក្សា កែលម្អប្រព័ន្ធ គ្រប់គ្រងទិន្នន័យមូលដ្ឋាន កំណត់លេខកូដ និងអភិវឌ្ឍផ្នែកទន់ដើម្បីអនុវត្តឱ្យមានការឯកភាព និងប្រសិទ្ធភាពនៃទិន្នន័យមូលដ្ឋាន

- បង្កើត រៀបចំវេបសាយ និងប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្សព្វផ្សាយអំពីរបាយការណ៍ និងស្ថិតិ

- ទទួលបន្ទុករៀបចំ និងអនុវត្តគោលការណ៍បែបបទប្រើប្រាស់ និងស្តង់ដារប្រព័ន្ធកុំព្យូទ័រ ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងទិន្នន័យ

- ត្រួតពិនិត្យការវាយបញ្ចូលទិន្នន័យ ការកែតម្រូវទិន្នន័យ សម្អាតកំហុសទិន្នន័យបឋម និងធ្វើការណែនាំការវាយបញ្ចូលទិន្នន័យដោយកុំព្យូទ័រ

- ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយទិន្នន័យមូលដ្ឋាន កម្មវិធីសម្រាប់បញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ

តាមការកំណត់របស់ឯកសារណែនាំ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិដល់អ្នកប្រើប្រាស់ អ្នកអភិវឌ្ឍផ្នែកទន់ អ្នកប្រើប្រាស់ស្ថិតិនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងសាធារណជន

- ស្រាវជ្រាវ និងដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រថ្មីៗក្នុងក្រសួង ដែលទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធបណ្តាញកុំព្យូទ័រ ការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការវិភាគ និងគ្រោង ការវាយបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ អ៊ិនធឺណេត អ៊ីម៉ែល វេបសាយ ។

**មាត្រា ៥.-**

នាយកដ្ឋានគណនេយ្យជាតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ប៉ាន់ស្មាន និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងនៃវិទ្យាស្ថានជាតិស្ថិតិ
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចជាតិ ការវិវត្តតាមវិស័យ អតិផរណា និងសន្ទស្សន៍ថ្លៃផ្សេងទៀត
- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ គណនីស្ថាប័ន គណនីលំហូរ គណនីចំណាយ គណនីមូលធន គណនីហិរញ្ញវត្ថុ គណនីពាណិជ្ជកម្មអន្តរជាតិ តារាងផ្គត់ផ្គង់ និងតារាងតម្រូវការ តារាងលំហូរគណនីចូល និងលំហូរគណនីចេញ តាមប្រព័ន្ធគណនេយ្យជាតិនៃអង្គការសហប្រជាជាតិ តាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំឆ្នាំ
- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ តាមវិស័យផលិតកម្ម និងចំណាយតាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំត្រីមាស
- អង្កេត ចងក្រង វិភាគ និងបោះផ្សាយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ ត្រីមាស សន្ទស្សន៍ថ្លៃអ្នកផលិតប្រចាំត្រីមាស សន្ទស្សន៍ថ្លៃឧស្សាហកម្មប្រចាំត្រីមាស សន្ទស្សន៍ថ្លៃនាំចេញ នាំចូលប្រចាំត្រីមាស សន្ទស្សន៍ថ្លៃកសិកម្មប្រចាំត្រីមាស និងសន្ទស្សន៍ថ្លៃផ្សេងទៀត
- ប្រមូល និងចងក្រងទិន្នន័យរដ្ឋបាល តាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីគាំទ្រការប៉ាន់ស្មានទិន្នផលស្ថិតិតាមវិស័យ និងគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- អង្កេត និងចងក្រងសូចនាករសេដ្ឋកិច្ចមួយចំនួន ដើម្បីធានាគុណភាពនៃការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ
- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រប៉ាន់ស្មានគណនី និងអនុវត្តពេញលេញតាមប្រព័ន្ធគណនេយ្យជាតិនៃអង្គការសហប្រជាជាតិ
- រៀបចំ និងចងក្រងសៀវភៅណែនាំស្តីពីប្រព័ន្ធគណនេយ្យជាតិ និងស្ថិតិថ្លៃ ។

**មាត្រា ៦.-**

នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម

- រៀបចំគោលនយោបាយក្នុងការពង្រឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហប្រតិបត្តិការស្ថិតិ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដល់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គភាពឯកជន និងសាធារណជន ឱ្យបានយល់ដឹងអំពីសារៈសំខាន់នៃស្ថិតិ
- រកដំណោះស្រាយក្នុងករណីមានបទល្មើសស្ថិតិ
- សហប្រតិបត្តិការស្ថិតិទ្វេភាគី ពហុភាគីក្នុងតំបន់ លើពិភពលោក និងសម្របសម្រួលការងារសម្រាប់អ្នកស្រាវជ្រាវស្ថិតិអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ដើម្បីផ្តល់ទិន្នន័យស្ថិតិ និងសេវាកម្មស្ថិតិ
- គ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញស្ថិតិ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីស្ថិតិក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- បូកសរុបសកម្មភាពការងារ និងធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តការងារស្ថិតិ របស់វិទ្យាស្ថានជាតិស្ថិតិ
- គ្រប់គ្រងលិខិតស្នាម និងតម្កល់ឯកសារ
- រៀបចំ និងគ្រប់គ្រងការងារចុះធ្វើសម្ភាសន៍ និងប្រមូលទិន្នន័យស្ថិតិ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភណ្ឌរបស់វិទ្យាស្ថានជាតិស្ថិតិ
- រៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពការងារស្ថិតិរយៈពេលខ្លី មធ្យម និងវែង
- ធ្វើគម្រោងថវិកាសម្រាប់ដំណើរការការងារស្ថិតិប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម និងវែងរបស់វិទ្យាស្ថានជាតិស្ថិតិ
- ធ្វើជាលេខាធិការដ្ឋានជូនគណៈកម្មាធិការសម្របសម្រួលស្ថិតិ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧.-**

មាត្រា ១២ ស្តីពីនាយកដ្ឋានស្ថិតិទូទៅនៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ